នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល





# បច្ចេកទេសចិញ្ចឹមជ្រូក



ឧបត្ថម្ភការបោះពុម្ពផ្សាយឡើងវិញដោយ គម្រោងកាត់បន្ថយភាពក្រីក្រ
និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចតំបន់ទន្លេសាប ADB Grant Nº 0186-CAM ( SF )

**ខែ កក្កដា ឆ្នាំ ២០១១**

សៀវភៅ "**បច្ចេកទេសចិញ្ចឹមជ្រូក**" នេះ បោះពុម្ពដោយគម្រោង អេម អេស អេម អ៊ី កម្ពុជា ដែលឧបត្ថម្ភថវិកាដោយទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ សំរាប់ប្រជាជនកម្ពុជា ដើម្បីពង្រឹងអាជីវកម្មចិញ្ចឹមជ្រូករបស់ពួកគេ។

**រៀបចំដោយ :** ក្រុមការងារគម្រោង អេម អេស អេម អ៊ី កម្ពុជា អង្គការ ឌី អេ អាយ។

**កែសម្រួលដោយ :** នាយកដ្ឋានផលិតកម្ម និងបសុព្យាបាលនៃក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ។

សៀវភៅនេះត្រូវបានចងក្រងដោយផ្អែកលើអនុសាសន៍ដ៏ថ្លៃថ្លា និងការចង្អុលបង្ហាញប្រកបដោយគតិបណ្ឌិតពី **ឯកឧត្តម បណ្ឌិត ចាន់ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ និងការណែនាំផ្តល់បច្ចេកទេសបន្ថែមពី **ឯកឧត្តម កៅ ផល** ប្រធាននាយកដ្ឋានផលិតកម្ម និងបសុព្យាបាល ដោយរួមបញ្ចូលនូវបទពិសោធន៍ បច្ចេកទេសល្អៗ ពីការិយាល័យផលិតកម្មនៃនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល។


**គម្រោង អេម អេស អេម អ៊ី កម្ពុជា**

**អាសយដ្ឋាន :**

អាគារ "F" ភ្នំពេញសិនធឺរ បន្ទប់លេខ ៥៨៨ ទន្លេបាសាក់ រាជធានីភ្នំពេញ

គេហទំព័រ : www.cambodiamsme.org

អ៊ីមែល : cambodiamsme@dai.com

ទូរស័ព្ទ : ៨៥៥-២៣ ២២២ ៤៩៦

ទូរសារ : ៨៥៥-២៣ ២២២ ៤៩៥



**សេចក្តីបញ្ជាក់ :** ទស្សនៈរបស់អ្នកនិពន្ធ ដែលបង្ហាញនៅក្នុងឯកសារបោះពុម្ពផ្សាយនេះ មិនបានឆ្លុះបញ្ចាំងអំពីទស្សនៈរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ ឬរដ្ឋាភិបាលអាមេរិកនោះទេ។



# អារម្ភកថា

ប្រទេសកម្ពុជា ជាប្រទេសកសិកម្ម។ បន្ទាប់ពីដំណាំស្រូវ ដែលជាប្រភពចំណូលដ៏សំខាន់សំរាប់កសិករខ្មែរ ប្រជាជនប្រមាណ ៧០ ភាគរយ ចិញ្ចឹមជ្រូកយ៉ាងតិចមួយក្បាល ដែលការចិញ្ចឹមជ្រូកនេះជាមុខរបរទីពីរ។

ប៉ុន្តែប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយសារកំនើនប្រជាជនកើនឡើង បណ្តាលឱ្យមានតំរូវការសាច់នៅលើទីផ្សារមានការកើនឡើងយ៉ាងខ្ពស់។ កត្តានេះជំរុញឱ្យវិស័យចិញ្ចឹមជ្រូកក្លាយជាឧស្សាហកម្មដ៏ធំមួយនៅក្នុងប្រទេស។ ប្រជាជនដែលប្រកបរបរចិញ្ចឹមជ្រូក ក៏មានចំនួនកាន់តែកើនច្រើនឡើងថែមទៀត។

នាពេលបច្ចុប្បន្ននេះ ឧស្សាហកម្មជ្រូកមានការលូតលាស់យ៉ាងខ្លាំង ដែលជាឱកាសសំរាប់កសិករចិញ្ចឹមជ្រូកស្វែងរកប្រាក់ចំណូលបន្ថែម ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ។ ដើម្បីបំពេញតំរូវការនៃការលូតលាស់ទាំងនេះ កសិករ ឬអាជីវករចិញ្ចឹមជ្រូក ត្រូវតែបង្កើនចំណេះដឹង ជំនាញ និងបទពិសោធន៍ថ្មីៗបន្ថែមទៀត ដើម្បីជំរុញបរិមាណ និងគុណភាពផលិតកម្មឱ្យបានខ្ពស់ បំពេញតំរូវការទីផ្សារ និងពង្រឹងភាពប្រកួតប្រជែងនៃឧស្សាហកម្មជ្រូកនៅក្នុងប្រទេសកម្ពុជា។

**គម្រោងពង្រឹងសហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យមកម្ពុជា (អេម អេស អេម អ៊ី កម្ពុជា)** ជាគម្រោងអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ចដែលកំពុងអនុវត្តដោយអង្គការ ឌី អេ អាយ ក្រោមជំនួយឧបត្ថម្ភរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ(USAID) ។គម្រោងធ្វើការជាមួយអាជីវករ ដើម្បីដោះស្រាយបញ្ហាប្រឈមនានាលើផ្នែកបច្ចេកទេស ផលិតកម្ម និងសេវាកម្ម ការទំនាក់ទំនង និងពង្រឹងបរិយាកាសអាជីវកម្ម។ ផ្នែកជ្រូក គឺជាសង្វាក់អាជីវកម្មមួយក្នុងចំណោមសង្វាក់អាជីវកម្មសំខាន់ៗជាច្រើន ដែលគម្រោងបាន និងកំពុងអនុវត្តនៅក្នុងខេត្តគោលដៅចំនួន ១២ គឺស្វាយរៀង ព្រៃវែង ក្រចេះ កំពង់ចាម កណ្ដាល ពោធិសាត់ បាត់ដំបង សៀមរាប កំពង់ធំ តាកែវ កំពត និងខេត្តកំពង់ស្ពឺ។ ទិសដៅសំខាន់នៅលើសង្វាក់អាជីវកម្មជ្រូកនេះ គឺបង្កើនចំណេះដឹង បច្ចេកទេស និងបទពិសោធន៍នៃការចិញ្ចឹម បង្កើនគុណភាព និងបរិមាណផលិតកម្ម បង្កើតបណ្ដាញទំនាក់ទំនង និងទីផ្សារ និងពង្រឹងបរិយាកាសអាជីវកម្មដែលមានលក្ខណៈអំណោយផលសំរាប់ឧស្សាហកម្មជ្រូកនៅក្នុងប្រទេសកម្ពុជា។

សៀវភៅ"**គន្លឹះជោគជ័យនៃបច្ចេកទេសចិញ្ចឹមជ្រូកនៅកម្ពុជា**" ត្រូវបានចងក្រងឡើង ដោយផ្អែកលើបទពិសោធន៍ជាក់ស្ដែងនៅក្នុងមុខរបរចិញ្ចឹមជ្រូក ដែលបានអនុវត្តនាពេលកន្លងមក។ ឯកសារនេះ បង្ហាញអំពីគន្លឹះសំខាន់ៗមួយចំនួននៃបច្ចេកទេសចិញ្ចឹមជ្រូក ដើម្បីទទួលបានជោគជ័យនៅក្នុងការចិញ្ចឹម ដោយផ្ដោតសំខាន់ទៅលើការជ្រើសរើសពូជ ការគ្រប់គ្រងចំណីការបង្កាត់ពូជ ការគ្រប់គ្រងមេជ្រូកផើម និងកូនជ្រូក ការគ្រប់គ្រងជ្រូកសាច់ ការគ្រប់គ្រងសុខភាពជ្រូកតាមបែបជីវៈសុវត្ថិភាព និងការគ្រប់គ្រងជំងឺជ្រូក។

យើងជឿជាក់ថា សៀវភៅនេះនឹងក្លាយជាមូលដ្ឋានគ្រឹះមួយសំរាប់អ្នកចិញ្ចឹម ដើម្បីអភិវឌ្ឍន៍ចំណេះដឹង និងបទពិសោធន៍របស់ខ្លួន ក៏ដូចជាជួយបំពេញចន្លោះប្រហោងនៃការចិញ្ចឹមជ្រូក ការគ្រប់គ្រងផលិតកម្មតាមបែបជីវៈសុវត្ថិភាព ដែលអាចធ្វើឱ្យអាជីវកម្មចិញ្ចឹមជ្រូករបស់អស់លោក-លោកស្រី ក្លាយជាមុខរបរដ៏ពិតប្រាកដមួយ ដើម្បីស្វែងរកប្រាក់ចំណូលសំរាប់ជីវភាពគ្រួសារ។



**លោក ឃីតឌីស ហាន់ដ៍លី**

**ប្រធានគម្រោង អេម អេស អេម អ៊ី កម្ពុជា**



# មាតិកា


**ជំពូក ១ ៖ ពូជជ្រូក ~ ការជ្រើសរើសជ្រូកបា និងជ្រូកមេក្រមុំ** ........ **១**

**I- ពូជនាំចូល** ........ **១**

១.១ ពូជ ឡាចវ៉ាយ (យ៉កសៀរ) ........ ១

១.២ ពូជ ឡៃនដ្រាស់ ........ ២

១.៣ ពូជ ឌុយរ៉ុក ........ ២

១.៤ ពូជ ភីតទ្រាន ........ ៣

១.៥ ពូជ ប៊ែកសាយ (Belk Shire) ........ ៤

១.៦ ពូជ ជ្រូកកូនកាត់ ........ ៤

**II- ពូជក្នុងស្រុក** ........ **៥**

**III- ការជ្រើសរើសជ្រូកបា និងជ្រូកមេក្រមុំ** ........ **៥**

**ជំពូក ២ ៖ ការសាងសង់ទ្រុង** ........ **៧**

២.១ ការជ្រើសរើសទីតាំង និងទំហំ តាមប្រភេទជ្រូក ........ ៧

២.២ កំរាលទ្រុង និងតំរូវការទីធ្លា ........ ៩

២.៣ ការប្រក់ដំបូលទ្រុងជ្រូក ........ ៩

**ជំពូក ៣ ៖ ការផ្តល់ចំណី និងទឹក** ........ **១០**

៣.១ ការផ្តល់ចំណី ........ ១០

៣.២ ការគ្រប់គ្រងចំណីទូទៅ ........ ១០

៣.៣ ការផ្តល់ទឹក ........ ១២

**ជំពូក ៤ ៖ ការបន្ទាត់ពូជ** ........ **១៣**

៤.១ ការគ្រប់គ្រងមេជ្រូកក្រមុំ ........ ១៣

៤.២ ការគ្រប់គ្រងមេជ្រូកផ្តាច់ដោះ ........ ១៤

៤.៣ ការបង្ខឹកជ្រូកបាក្មេង ........ ១៤

៤.៤ វដ្តនៃការរកឈ្មោល ការបង្កាត់តាមធម្មជាតិ និងសិប្បនិម្មិត ........ ១៥

**ជំពូក ៥ : ជ្រូកមេដើម** ........ **១៦**
- ៥.១ ការត្រួតពិនិត្យ និងការកត់ត្រាមេជ្រូកធើម ........ ១៦
- ៥.២ ការផ្តល់ចំណី និងសុខភាពជ្រូក ........ ១៦

**ជំពូក ៦ : ការកើតកូន** ........ **១៧**
- ៦.១ មុនពេលកើត ក្នុងពេលកើត និងក្រោយពេលកើតកូន ........ ១៧
  - *៦.១.១. មុនពេលកើត ........ ១៧*
  - *៦.១.២. ក្នុងពេលកើត ........ ១៨*
  - *៦.១.៣. ក្រោយពេលកើត ........ ១៩*
- ៦.២ ការថែរក្សាសុខភាពកូនជ្រូកទើបកើត និងមេជ្រូក ........ ២៣
- ៦.៣ បញ្ហាសាមញ្ញៗ ដែលច្រើនកើតមានលើមេជ្រូក និងកូនជ្រូក ........ ២៣

**ជំពូក ៧ : ការថែទាំ ការផ្តាច់ដោះ និងទ្រុងសំរាប់កូនជ្រូកផ្តាច់ដោះ** ........ **២៤**

**ជំពូក ៨ : ជ្រូកជំទង់ និងជ្រូកសាច់** ........ **២៧**

**ជំពូក ៩ : ការត្រួតពិនិត្យ និងកត់ត្រាផលិតផល** ........ **២៨**

**ជំពូក ១០ : ការត្រួតពិនិត្យសុខភាពជ្រូក** ........ **៣០**
- ១០.១ ការធ្វើអនាម័យ និងវិធានការការពារសុខភាពសត្វ ........ ៣០
- ១០.២ គោលការណ៍ការពារជំងឺ ........ ៣១

**ជំពូក ១១ : ជំងឺជ្រូក** ........ **៣៣**
- ១១.១ ជំងឺប៉េស្តជ្រូក ........ ៣៣
- ១១.២ ជំងឺត្រចៀកខៀវ ........ ៣៤
- ១១.៣ ជំងឺរាកកូនជ្រូក ........ ៣៥
- ១១.៤ ជំងឺផ្លូវដង្ហើម ........ ៣៧
- ១១.៥ ជំងឺអូហ្សេស្គី ........ ៤០

**ឯកសារយោង** ........ **៤១**



# ជំពូក ១ ៖ ពូជជ្រូក

ជាទូទៅ ពូជជ្រូកសំរាប់ផលិតកម្មជ្រូកបែបឧស្សាហកម្មភាគច្រើន គឺ ឡាចវ៉ាយ (Large white) ឡែនដ្រាស់ (Landrace) និងពូជជ្រូកឌុយរ៉ុក (Duroc) ឬពូជកូនកាត់។ ពូជទាំង ៣ ប្រភេទនេះ ផលិតសាច់ក្រហម ដោយរួមផ្សំជាមួយនឹងប្រសិទ្ធភាពរបស់ចំណីផងដែរ (២,៥-២,៨ គ.ក នៃចំណីមានគុណភាពផលិតបានសាច់ជ្រូក ១ គ.ក)។ តែបើប្រៀបធៀបទៅនឹងពូជជ្រូកក្នុងស្រុក ពូជជ្រូកនាំចូលទាំងនេះមិនសូវធន់ទៅនឹងជំងឺ ហើយងាយរងនូវបញ្ហាផ្សេងៗពីអាកាសធាតុក្តៅ និងចំណីដែលមានគុណភាពអន់។

## I- ពូជនាំចូល

### ១.១ ពូជឡាចវ៉ាយ (យ៉កសៀរ)

ពូជ ឡាចវ៉ាយ មានប្រភពដើមពីប្រទេសអង់គ្លេស។ វាមានសំបុរពណ៌ស ជាមេពូជល្អផលិតកូនបានច្រើន។ ពូជជ្រូកនេះលូតលាស់លឿន និងផលិតសាច់ក្រហមច្រើន និងមានគុណភាពល្អ។

**លក្ខណៈរបស់ពូជជ្រូកនេះ គឺ**

- ដងខ្លួនពណ៌សពេញខ្លួនទាំងស្រុង រោមពណ៌ស ហើយរឹង ស្លឹកត្រចៀកតូច ហើយត្រង់
- ក្បាលតូច ត្រចៀកបញ្ឈរ កធំ ហើយខ្លី
- ស្មាធំសំបូរសាច់ ខ្នងត្រង់រហូតដល់ត្រគាក
- ដងខ្លួនវែង ជើងរឹងមាំ ច្រមុះខ្លី



## ១.២ ពូជឡែនដ្រាស់

ពូជ ឡែនដ្រាស់ មានប្រភពដើមពីប្រទេសដាណឺម៉ាក។ វាជាពូជជ្រូកដែលមានដងខ្លួនវែងជាងពូជប្រភេទផ្សេង។ វាជាមេពូជដែលផលិតកូនបានច្រើន ផ្ទាំងសាច់មានគុណភាពល្អ ប៉ុន្តែជើងក្រោយរបស់វាតូច មិនសូវរឹងមាំ។

### លក្ខណៈរបស់ពូជឡែនដ្រាស់ គឺ

- រោម និងស្បែក ពណ៌សសុទ្ធ
- ត្រចៀកធំធ្លាក់ទៅមុខបន្តិចគ្របភ្នែក ចុងត្រចៀកក្ដោបចូល
- ក្បាលតូច និងច្រមុះវែង មាត់វែងឡើងលើបន្តិច
- ត្រគាកធំ និងខ្នងកោង ស្មាតូច ឆ្អឹងតូច ជើងតូច ហើយជំហរត្រង់



## ១.៣ ពូជឌុយរ៉ុក

ពូជឌុយរ៉ុក មានប្រភពដើមមកពីប្រទេសអាមេរិក។ វាមានសាច់ដុំធំល្វតលាស់លឿនផលិតសាច់បានល្អ និងធន់នឹងបញ្ហាស្ត្រេស។

**លក្ខណៈរបស់ពូជជ្រូកនេះ គឺ**

- សំបុរពណ៌ត្នោត
- ត្រចៀកមធ្យម និងធ្លាក់បន្តិច
- ក្បាលធំ ច្រមុះខ្លី ហើយត្រង់
- ត្រគាកធំ ស្មាធំដូចត្រគាកដែរ ឆ្អឹងធំ ហើយខ្ពស់
- ជើងទាំងបួនមានជំហរត្រង់



## ១.៤ ពូជភីតទ្រាន

ពូជនេះមានអុចស និងខ្មៅ ត្រចៀកត្រង់បន្តិចមានសាច់ដុំភ្លៅធំ សាច់ចំឡក ប្រភពដើមមកពីប្រទេសហូឡង់។ វាមានសាច់ដុំធំល្វតលាស់លឿនផលិតសាច់បានល្អ និងធន់នឹងបញ្ហាស្រ្តេស។

**លក្ខណៈរបស់ពូជជ្រូកនេះ គឺ**

- សំបុរពណ៌ ស ខ្មៅ (ខ្លាឃ្មោក)
- ត្រចៀកមធ្យម និងត្រង់បន្តិច
- ក្បាលធំ ច្រមុះខ្លី ហើយត្រង់
- ត្រគាកធំ ជើងខ្លី ស្មារីក
- កំពស់ទាប ជំហរត្រង់

